ព្រះរាជាណាចក្រកម្ពុជា

ជាតិសាសនាព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# គោលនយោបាយជាតិ

# ដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ

ខែ កញ្ញា ឆ្នាំ ២០១៤

# មាតិកា


អក្សរកាត់ IV

អារម្ភកថា V

សេចក្តីថ្លែងអំណរគុណ VII

គោលការណ៍ណែនាំ 1

គោលបំណង 1

ចក្ខុវិស័យ 1

បេសកកម្ម 1

វិសាលភាព 2

គោលដៅ 3

គោលដៅទូទៅនៃគោលនយោបាយ 3

គោលដៅជាក់លាក់នៃគោលនយោបាយ 3

ក្របខ័ណ្ឌយុទ្ធសាស្ត្រ 4

1. រៀបចំផែនការជាតិគ្រប់ជ្រុងជ្រោយ 5

*ក. ការសម្របសម្រួលកម្មវិធីជាតិដើម្បីទប់ស្កាត់AMR ដោយរដ្ឋាភិបាល* 5

*ខ. គម្រោងថវិកាចំណាយសម្រាប់ផែនការនិងការគៀងគរធនធាន* 7

*គ. កសាងភាពជាដៃគូជាមួយសង្គមស៊ីវិល* 7

**2. ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍សម្រាប់ AMR** **8**

*ក. កសាងសមត្ថភាពសម្រាប់ការធ្វើតេស្តរោគវិនិច្ឆ័យរហ័សនិងអាចជឿទុកចិត្តបាន* 8

**3. ពង្រឹងការតាមដាន AMR** **9**

*ក. បង្កើតប្រព័ន្ធតាមដាននិងត្រួតពិនិត្យAMR* 9

**4. ធានាការទទួលបានឱសថប្រឆាំងមេរោគដែលមានគុណភាព** **10**

ក. ពង្រឹងប្រព័ន្ធផ្គត់ផ្គង់ឱសថសារវ័ន្តប្រឆាំងមេរោគ 10

*ខ. ធានាគុណភាពឱសថយោងតាមស្តង់ដារដែលអាចទទួលយកបាន* 11

**5. ធ្វើនិយ័តកម្មនិងលើកកម្ពស់ការប្រើឱសថដោយសមស្រប** **12**

*ក. លើកកម្ពស់ និងពង្រឹងមគ្គុទ្ទេសក៍ព្យាបាលស្តង់ដារ* 12

*ខ. ដាក់បញ្ចូលជាផ្លូវការកម្មវិធីដឹកនាំឱសថប្រឆាំងមេរោគ ទៅក្នុងមូលដ្ឋានសុខាភិបាល* 14

*គ. លើកកម្ពស់ការអប់រំអំពីឱសថប្រឆាំងមេរោគ និងការប្រើឱសថទាំងនេះឲ្យបានត្រឹមត្រូវ។* 14

ឃ. កាត់បន្ថយគ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដែលលើកទឹកចិត្តដល់ការប្រើឱសថដោយមិនសមស្រប 15

ង. កាត់បន្ថយការប្រើឱសថប្រឆាំងមេរោគនៅក្នុងបសុសត្វ 16

**6. លើកកម្ពស់ការបង្ការនិងការត្រួតពិនិត្យការចម្លងរោគ** **18**

ក. អនុវត្តកម្មវិធីបង្ការនិងត្រួតពិនិត្យការចម្លងរោគនៅគ្រប់មូលដ្ឋានសុខាភិបាល 18

ខ. លើកកម្ពស់និងវាយតម្លៃការអនុវត្តស្តង់ដារបង្ការនិងត្រួតពិនិត្យការចម្លងរោគ 19

7. ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍន៍រកឧបករណ៍ថ្មីៗ **20**

**ក្របខ័ណ្ឌអនុវត្តន៍ 21**

I. **ការទទួលខុសត្រូវរួម 21**

II. **តួនាទីនិងការទទួលខុសត្រូវរបស់ដៃគូដទៃទៀត 21**

III. **ក្របខ័ណ្ឌប្រតិបត្តិ 23**

IV. **ការពិនិត្យឡើងវិញនិងការវាយតម្លៃ 23**

# អក្សរកាត់

| | |
|---|---|
| AMR | ភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ |
| AMR CSA | ការវិភាគស្ថានភាពរបស់ប្រទេសស្តីពីភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ |
| AMR WG | ក្រុមការងារទប់ស្កាត់ភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ |
| AST | ការធ្វើតេស្តប្រសិទ្ធភាពឱសថប្រឆាំងមេរោគ |
| CPG | គោលការណ៍ណែនាំស្តីពីការអនុវត្តគ្លីនិក |
| DDF | នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសំអាង |
| IPC | ការបង្ការ និងត្រួតពិនិត្យការចម្លងរោគ |
| MoH | ក្រសួងសុខាភិបាល |
| NPCAR | គោលនយោបាយជាតិដើម្បីទប់ស្កាត់ភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ |
| OIE | អង្គការសុខភាពសត្វពិភពលោក |
| TRIPS | ទិដ្ឋភាពដែលទាក់ទងនឹងពាណិជ្ជកម្មនៃកម្មសិទ្ធិបញ្ញា |
| VAT | អាករលើតម្លៃបន្ថែម |
| WHO | អង្គការសុខភាពពិភពលោក |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

# អារម្ភកថា

ភាពស៊ាំរបស់មេរោគទៅនឹងឱសថប្រឆាំងមេរោគ(AMR)គឺជាភាពស៊ាំរបស់អតិសុខុមប្រាណមួយទៅនឹងឱសថប្រឆាំងមេរោគ ដែលធ្លាប់តែមានប្រសិទ្ធភាពពីមុនមក។ បាក់តេរី វីរុសផ្សិត និងប៉ារ៉ាសិត ដែលមានភាពស៊ាំអាចមានសមត្ថភាពទប់ទល់នឹងឥទ្ធិពលរបស់ថ្នាំប្រឆាំងមេរោគ (ឧទា. អង់ទីប៊ីយ៉ូទិក ឱសថប្រឆាំងវីរុស ឱសថព្យាបាលជំងឺគ្រុនចាញ់ ឱសថប្រឆាំងពពួកមេរោគផ្សិត)។ បញ្ហានេះធ្វើឲ្យការព្យាបាលតាមស្តង់ដាទៅជាគ្មានប្រសិទ្ធភាព និងធ្វើឲ្យសហគមន៍ទៅជាងាយរងគ្រោះព្រោះការបង្ករោគដែលមានភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ អាចរីករាលដាល។

ក្រសួងសុខាភិបាលប្តេជ្ញាចិត្តធ្វើការដឹកនាំនៅក្នុងការផ្តល់សេវាលើគ្រប់ផ្នែកទាំងអស់នៃវិស័យសុខាភិបាល ស្របតាមទិសដៅគោលនយោបាយរបស់ខ្លួនដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្រ្តសុខាភិបាល (២០០៨-២០១៥) គោលនយោបាយជាតិដើម្បីទប់ស្កាត់ភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគផ្តោតទៅលើគោលការណ៍សំខាន់ៗដូចខាងក្រោម÷

- ការទទួលបានការថែទាំសុខភាពប្រកបដោយគុណភាពគឺជាសិទ្ធិមនុស្សជាមូលដ្ឋានមួយដែលរាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវជាចម្បង។
- ការថែទាំសុខភាពប្រកបដោយគុណភាពរួមមានវិធានការបង្ការនិងទប់ស្កាត់ ភាពស៊ាំ ទៅនឹងឱសថប្រឆាំងមេរោគ (AMR)។
- AMR គឺជាការគំរាមកំហែងផ្នែកសុខភាពសាធារណៈដ៏ធំមួយ ដែលបង្កផលវិបាកអវិជ្ជមានយ៉ាងធំធេងដល់ផ្នែកសុខភាពនិងសេដ្ឋកិច្ច។
- កម្មវិធីដែលមានជោគជ័យមួយដើម្បីប្រយុទ្ធប្រឆាំងភាពស៊ាំនឹងឱសថប្រឆាំងមេរោគតម្រូវឲ្យមានយុទ្ធសាស្រ្តមួយគ្រប់ជ្រុងជ្រោយ បែបសមាហរណកម្មនិងអន្តរវិស័យពហុជំនាញ និងដែលមានការចូលរួមពីពហុជំនាញនិងភាគីពាក់ព័ន្ធជាច្រើន។

នេះគឺជាគោលនយោបាយជាតិទីមួយ ដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នៅក្នុងប្រទេសកម្ពុជា។ គោលនយោបាយជាតិនេះត្រូវបានរៀបចំឡើងដោយផ្អែកលើសេចក្តីសន្និដ្ឋាននិងអនុសាសន៍ពីការវិភាគស្ថានភាពនៃ

ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) នៅក្នុងប្រទេសដែលបានធ្វើឡើងនៅក្នុងឆ្នាំ២០១៣ និងផ្តល់នូវក្របខ័ណ្ឌត្រួតពិនិត្យមួយដើម្បីបង្កើត និងពង្រឹងវិធានការនានាដើម្បីទប់ស្កាត់ការកើតឡើង និងការរីករាលដាលនៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅក្នុងប្រទេស។ ការអនុវត្តគោលនយោបាយនេះ និងផែនការយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងគោលនយោបាយនេះ តម្រូវឱ្យមានថវិកាយ៉ាងច្រើន និងការប្តេជ្ញាចិត្តផ្នែកនយោបាយកម្រិតខ្ពស់។ដោយសារតែ AMR គឺជាបញ្ហាពហុជំនាញនិងអន្តរវិស័យ ការអនុវត្តដោយជោគជ័យនូវគោលនយោបាយនេះ តម្រូវឱ្យមានការសម្របសម្រួលនិងសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ក្នុងចំណោមវិស័យផ្សេងៗជាច្រើន។

ការអភិវឌ្ឍន៍គោលនយោបាយនេះ មានការខិតខំប្រឹងប្រែងរួមគ្នានៃភាគីពាក់ព័ន្ធជាច្រើន ដែលរួមមានក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាគមវិជ្ជាជីវៈ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងស្រាវជ្រាវ និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការចូលរួមចំណែកដ៏មានតម្លៃរបស់ស្ថាប័ន និងអង្គការមានជាអាទិ៍ ក្រុមការងារទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង នៃក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក ដែលបានផ្តល់ការគាំទ្រផ្នែក បច្ចេកទេស និងសម្ភារៈដល់ការអភិវឌ្ឍន៍ និងការបង្កើយនូវឯកសារគោលនយោបាយនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី...០៦...ខែ មិនា ឆ្នាំ ២០១៥

ជ. រដ្ឋមន្ត្រីក្រសួងសុខាភិបាល

រដ្ឋលេខាធិការ

សាស្ត្រាចារ្យ អេង ហួត

# សេចក្តីថ្លែងអំណរគុណ

តាងនាមឲ្យក្រសួងសុខាភិបាល ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ លោក លោកស្រីដែលបានចូលរួមចំណែកផ្តល់ការគាំទ្រដល់ការអភិវឌ្ឍន៍ និងការបង្ហើយញ្ចប់ចុងក្រោយនៃគោលនយោបាយជាតិដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគនេះ។

| | |
|---|---|
| ឯ.ឧ.ម៉ម ប៊ុនហេង | រដ្ឋមន្ត្រីក្រសួងសុខាភិបាល |
| ឯ.ឧ.សាស្ត្រាចារ្យ អេង ហួត | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល |
| ឯ.ឧ.សាស្ត្រាចារ្យ ស៊ា ហ្វង | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល |
| វេជ្ជ. ឱ វណ្ណឌីន | អគ្គនាយិការបច្ចេកទេស ក្រសួងសុខាភិបាល |
| វេជ្ជ. ខាត់ សុផល | សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| វេជ្ជ. សុខ ទូច | អតីតប្រធាន នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| វេជ្ជ. លី សូវ៉ាន់ | ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| វេជ្ជ. សាន់ សារី | អតីតប្រធាននាយកដ្ឋានសេវាមន្ទីរពេទ្យ |
| ឱសថបណ្ឌិត ហេង ប៊ុនគៀត | ប្រធាននាយកដ្ឋានឱសថនិងចំណីអាហារ |
| វេជ្ជ. ប្រាក់ ពិសិដ្ឋរង្សី | ប្រធាននាយកដ្ឋានការពារសុខភាព |
| លោក.ហុក ខៀវ | ប្រធាននាយកដ្ឋាននីតិកម្ម |
| វេជ្ជ. ថាច វ៉ារ៉ុន | អតីតអនុប្រធាននាយកដ្ឋានការពារសុខភាព |
| វេជ្ជ. សុខ ស្រ៊ុន | ប្រធាននាយកដ្ឋានសេវាមន្ទីរពេទ្យ |
| វេជ្ជ. សៅ សុគន្ធណា | អនុប្រធាននាយកដ្ឋានសេវាមន្ទីរពេទ្យ |
| ឱសថបណ្ឌិត យ៉ង់ ដារ៉ាវុធ | អនុប្រធាននាយកដ្ឋានឱសថនិងចំណីអាហារ |
| វេជ្ជ. ប៊ុន ស្រេង | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |

| | |
|---|---|
| វេជ្ជ. ខេង ស៊ីម | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| វេជ្ជ. ទាម បាក់ឃីម | អតីតអនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺរបេងនិងហង់សិន |
| វេជ្ជ. ណារិទ្ធ រដ្ឋា | មន្ត្រីវេជ្ជសាស្ត្រមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺរបេងនិងហង់សិន |
| វេជ្ជ. លឹម យី | អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែកនិងកាមរោគ |
| វេជ្ជ. ឡឹក ឪស្វូឡី | អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់បាណកសាស្ត្រនិងប៉ារ៉ាសិតសាស្ត្រ |
| ឱសថការី ប៊ុត សុខល | អនុប្រធានវិទ្យាស្ថានជាតិសុខភាពសាធារណៈ |
| សាស្ត្រាចារ្យ ឈា ឆវណ្ណ | អនុប្រធានវិទ្យាស្ថានជាតិសុខភាពសាធារណៈ |
| សាស្ត្រាចារ្យ អៀម សុផល | នាយកសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| សាស្ត្រាចារ្យ ជូ មុនីដារិន | ព្រឹទ្ធបុរសរងមហាវិទ្យាល័យឱសថសាស្ត្រសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| សាស្ត្រាចារ្យ គង់ សន្យា | អគ្គនាយករង មន្ទីរពេទ្យកាល់ម៉ែត |
| វេជ្ជ. ហាក់ ស៊ីថន | ប្រធានការិយាល័យសុខភាពមាត់ធ្មេញនាយកដ្ឋានការពារសុខភាព |
| លោក អាំង ហុកស្រ៊ុន | ប្រធានការិយាល័យសុវត្ថិភាពចំណីអាហារ នាយកដ្ឋានឱសថនិងចំណីអាហារ |
| វេជ្ជ. ជី ស៊ីរុទ្ធិ | ប្រធានការិយាល័យសេវាមន្ទីរពេទ្យនិងវិស្វកម្មជីវវេជ្ជសាស្ត្រនាយកដ្ឋានសេវាមន្ទីរពេទ្យ |
| វេជ្ជ. ឱ ឧត្តមរដ្ឋ | ប្រធានការិយាល័យឱសថសារវ័ន្តនាយកដ្ឋានឱសថនិងចំណីអាហារ |
| វេជ្ជ. សេង ហេង | ប្រធានការិយាល័យតាមដាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |

| | |
|---|---|
| វេជ្ជ. យី សេងឡឿន | អនុប្រធានការិយាល័យតាមដាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| វេជ្ជ. ឈី សុខុម | អនុប្រធានការិយាល័យចត្តាឡីស័កនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| វេជ្ជ. ហុក ស៊ីរ៉ានី | អនុប្រធានការិយាល័យនាយកដ្ឋានការពារសុខភាព |
| ឱសថការី ស៊ា ថុល | អនុប្រធានការិយាល័យឱសថសារវ័ន្តនាយកដ្ឋានឱសថនិងចំណីអាហារ |
| ឱសថការី អ៊ុក រមនា | ប្រធានផ្នែកគ្រប់គ្រងសំណល់ថៃទាំវេជ្ជសាស្រ្តការិយាល័យសេវាមន្ទីរពេទ្យនាយកដ្ឋានសេវាមន្ទីរពេទ្យ |
| វេជ្ជ. ស៊ុត ថងផាន់ | មន្រ្តីវេជ្ជសាស្រ្តមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| វេជ្ជ. ណារិទ្ធ រដ្ឋា | មន្រ្តីវេជ្ជសាស្រ្តមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺរបេង |
| វេជ្ជ. ប៉ូរី សុថារិទ្ធ | មន្ទីរពេទ្យកាល់ម៉ែត |
| ឱសថការី អេង ឡេងស៊ា | ប្រធានផ្នែកមន្ទីរពិសោធន៍មន្ទីរពេទ្យកាល់ម៉ែត |
| វេជ្ជ. លឹម ណារិន | មន្ទីរពេទ្យកុមារជាតិ |
| វេជ្ជ. គង់ ពិសិដ្ឋ | អនុប្រធានមន្ទីរពេទ្យព្រះអង្គឌួង |
| វេជ្ជ. ទូច ឃុន | អនុប្រធានមន្ទីរពេទ្យព្រះកុសមៈ |
| វេជ្ជ. ចាន់ វិចិត្រ | អនុប្រធានមន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀត |
| លោកស្រី វេង មុំ | អភិបាលនៃផ្នែកមីក្រូជីវសាស្រ្តវិទ្យាស្ថានជាតិសុខភាពសាធារណៈ |
| សាស្រ្តាចារ្យ ឡាំ អេងហួរ | សមាគមគ្រូពេទ្យកម្ពុជា |
| សាស្រ្តាចារ្យ ឌួង ប៊ុន | សមាគមគ្រូពេទ្យកម្ពុជា |
| ឱសថការី កួវ ប៊ុនតោ | សមាគមឱសថការីកម្ពុជា |
| លោក អ៊ុង សាន | សមាគមគិលានុបដ្ឋាកកម្ពុជា |

| | |
|---|---|
| លោកស្រី អ៊ឹង រ៉ាដា | ប្រធានគណៈឆ្មបកម្ពុជា |
| លោក ពេជ្រ ប៉េដា | អនុប្រធានការិយាល័យបសុសត្វក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ |
| វេជ្ជ. ឈឹម វុត្ថា | អនុប្រធាន ការិយាល័យក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ |
| វេជ្ជ. ហួល ដារ៉ុន | អនុប្រធានវិទ្យាស្ថានជាតិស្រាវជ្រាវបសុសត្វ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ |
| លោកស្រី សុខ គាំ | អនុប្រធានផ្នែកមីក្រូជីវសាស្ត្រក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ |
| វេជ្ជ. សៅស៊ី ដូណា | នាយកដ្ឋានសុខភាពក្រសួងការពារជាតិ |
| វេជ្ជ. ចាន់ ម៉ាសែល | មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| លោក អ៊ីវ ផល្លី | មន្ត្រីក្រសួងព័ត៌មាន |
| លោក ហ៊ុន ហ្សីឌីឡា | មន្ត្រីបច្ចេកទេសក្រសួងអប់រំយុវជននិងកីឡា |
| វេជ្ជ. Alex Costa | មន្ត្រីបច្ចេកទេស WHO Cambodia |
| លោក Roderick Layug Salenga | ទីប្រឹក្សាបច្ចេកទេស WHO |
| វេជ្ជ. Lilen Dorothy Cruz Sarol | ទីប្រឹក្សាបច្ចេកទេសWHO |
| វេជ្ជ. Lotfi Allal | FAO Cambodia |
| លោកស្រី  Sophie Goyet | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| វេជ្ជ. Erika Vlieghe | វិទ្យាស្ថានវេជ្ជសាស្ត្រតំបន់ត្រូពិក បែលហ្ស៊ិក |
| វេជ្ជ. Alexendra Kerlguer | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| វេជ្ជ. គ្រុយ ស៊ុនឡាយ | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| លោកស្រី. ហែម សុភ័ក្រ | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| វេជ្ជ. ផៃ ថុង | មន្ទីរពេទ្យព្រះសីហនុ មណ្ឌលនៃក្ដីសង្ឃឹម |

ឱសថការី កៅ មុយលីម តំណាងក្រុមហ៊ុនឱសថកម្ពុជា

*លេខាធិការដ្ឋាន:*

វេជ្ជ. ប៊ុន ស្រេង អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

វេជ្ជ. ក្រង ស៊ីដន អនុប្រធានការិយាល័យបង្ការនិងត្រួតពិនិត្យនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

លោកស្រី. ជា សុបុណ្ណៈ មន្ត្រីនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

## សេចក្ដីផ្ដើម

នៅក្នុងទសវត្សរ៍ ១៩៤០ ការដាក់ឲ្យប្រើប្រាស់ឱសថប្រឆាំងមេរោគទៅក្នុងការអនុវត្តវេជ្ជសាស្រ្ត បានធ្វើឲ្យមានការផ្លាស់ប្ដូរដល់សមត្ថភាពរបស់យើងក្នុងការព្យាបាលជំងឺឆ្លង។ទោះបីជាយ៉ាងនេះក្ដី គ្រាន់តែរយៈពេលពីរបីទសវត្សក្រោយមកប៉ុណ្ណោះ អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលនៅជុំវិញសកលលោក មិនអាចរំពឹងទៀតទេថា ឱសថប្រឆាំងមេរោគនឹងនៅតែមានប្រសិទ្ធភាពឡើយ ដោយសារតែការលេញចេញនូវភាពស៊ាំទៅនឹង ឱសថ។ បច្ចុប្បន្ននេះ ភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ (AMR)បានក្លាយទៅជាបញ្ហាទូទៅនៅក្នុងបរិបទគ្លីនិកនិងសហគមន៍ ហើយបង្កជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរមួយចំពោះសុខភាពជាសកលដែលតម្រូវឲ្យមានវិធានការភ្លាមៗនិងជាបន្ទាន់។

ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) គឺជាសមត្ថភាពរបស់មេរោគក្នុងការលូតលាស់ជាមួយវត្តមានឱសថមួយដែលធ្លាប់តែសម្លាប់វាបានឬបញ្ឈប់ការលូតលាស់របស់វា។ទោះបីជាវាគឺជាបាតុភូតនៃការវិវត្តន៍តាមធម្មជាតិដោយសារតែមេរោគសម្របខ្លួនវាទៅនឹងឱសថប្រឆាំងមេរោគដែលផលិតតាមធម្មជាតិក៏ដោយ បញ្ហាគឺបណ្ដាលមកពីការប្រើប្រាស់ដោយមិនសមស្របនូវឱសថប្រឆាំងមេរោគ ដែលជាហេតុធ្វើឲ្យភាពស៊ាំរបស់វាវិវឌ្ឍកាន់តែលឿន។ AMRធ្វើឲ្យកើនឡើងនូវអត្រាឈឺអត្រាស្លាប់និងការចំណាយលើការថែទាំសុខភាព គំរាមកំហែងដល់សន្តិសុខសុខភាព និងធ្វើឱ្យខូចខាតពាណិជ្ជកម្មនិងសេដ្ឋកិច្ច។ **AMRរារាំងដល់ការប្រយុទ្ធនឹងជំងឺឆ្លងដែលបង្ករឲ្យការស្លាប់កាន់តែច្រើនដោយសារជំងឺ ដែលមិនអាចព្យាបាលបាន។**

នៅក្នុងឱកាសទិវាសុខភាពពិភពលោកឆ្នាំ២០១១ អង្គការសុខភាពពិភពលោក (WHO) បានជំរុញឲ្យរដ្ឋជាសមាជិក ប្ដេជ្ញាចិត្តអនុវត្តផែនការជាតិគ្រប់ជ្រុងជ្រោយដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគនិងបញ្ចេញកញ្ចប់គោលនយោបាយមួយដើម្បីប្រយុទ្ធនឹង AMR[1] ដោយគ្របដណ្ដប់លើផ្នែកជាគន្លឹះចំនួន៦ដែលត្រូវបានអនុម័តនៅក្នុងការអភិវឌ្ឍគោលនយោបាយដូចខាងក្រោមនេះ÷

- ប្ដេជ្ញាចិត្តអនុវត្តផែនការជាតិគ្រប់ជ្រុងជ្រោយ ដែលមានថវិកាគ្រប់គ្រាន់ ប្រកបដោយគណនេយ្យភាពនិងការចូលរួមពីសង្គមស៊ីវិល។

[1] http://www.who.int/world-health-day/2011/policybriefs/en/index.html

- ពង្រឹងការតាមដាននិងសមត្ថភាពមន្ទីរពិសោធន៍។
- ធានាការទទួលបានជាបន្តនូវឱសថសារវន្តដែលមានការធានាគុណភាព។
- ធ្វើនិយ័តកម្មនិងលើកកម្ពស់ការប្រើឱសថសមស្រប រួមទាំងនៅក្នុងវិស័យផលិតកម្មសត្វ និងធានាការថែទាំអ្នកជំងឺបានត្រឹមត្រូវ។
- លើកកម្ពស់ការបង្ការនិងការត្រួតពិនិត្យការចម្លងរោគ។
- ជំរុញការស្រាវជ្រាវនិងការអភិវឌ្ឍន៍សម្រាប់រកឧបករណ៍ថ្មីៗ។

ការប្រើមិនសមស្រុបនូវឱសថប្រឆាំងមេរោគនៅក្នុងប្រទេសកម្ពុជា គឺជាបញ្ហាដែលកើតឡើងជាទូទៅហើយត្រូវបានគេជឿថា បានរួមចំណែកដល់ការកើតឡើងនូវភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគជាច្រើនមុខ។ ភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគបានកើតឡើងក្នុងលក្ខណៈរ៉ាំរ៉ៃនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃចំនួនបីជងកន្លងមក[2] , ក្រោយមកទៀតបានរីករាលដាលទៅតំបន់អាស៊ីអាគ្នេយ៍ (SEA) និងអាហ្វ្រិកនិងរួមចំណែកដល់ការកើតឡើងនូវជំងឺគ្រុនចាញ់ក្នុងសកលលោកក្នុងរយៈពេលបីទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០។ភាពស៊ាំទៅនឹងឱសថអាតេមីស៊ីនីន (Artemisinin) បានកើតឡើងក្នុងពេលថ្មីៗ ហើយត្រូវបានគេប្រកាសថាជាគ្រោះអាសន្នសុខភាពសកលលោកមួយដោយហេតុថាបច្ចុប្បន្ននេះ ពុំមានឱសថជំនួសណាមួយដើម្បីទប់ស្កាត់ជំងឺមួយដែលសម្លាប់មនុស្សប្រមាណ១លាននាក់ជារៀងរាល់ឆ្នាំជុំវិញពិភពលោក។ឧប្បត្តិហេតុនៃជំងឺរបេងដែលស៊ាំនឹងឱសថច្រើនមុខ (Multi-Drug Resistant TB (MDR-TB)) បាននិងកំពុងកើនឡើងក្នុងចំណោមអ្នកជំងឺដែលបានព្យាបាលកន្លងមកនៅក្នុងប្រទេសកម្ពុជានិងត្រូវបានប៉ាន់ស្មានថាមាន១១% (២០១១) [3] ប្រៀបធៀបនឹង ១០,៣% ក្នុងឆ្នាំ២០០៧[4] និង៣,១% ក្នុងឆ្នាំ២០០១[5]។ទិន្នន័យមន្ទីរពិសោធន៍ បង្ហាញថាភាពស៊ាំនឹងឱសថអង់ទីប៊ីយ៉ូទិកដែលត្រូវបានគេប្រើប្រាស់ភាគច្រើនបំផុតនៅក្នុងប្រទេសកម្ពុជាមានកម្រិតខ្ពស់យ៉ាងខ្លាំងក្នុងចំណោម

[2] http://www.wwarn.org/resistance/malaria/history

[3] https://extranet.who.int/sree/Reports?op=Replet&name=/WHO_HQ_Reports/G2/PROD/EXT/TBCountryProfile&ISO2=KH&outtype=html

[4] National Tuberculosis Drug Resistance Survey 2006-2007, CENAT, May 2011: http://www.cenat.gov.kh/sites/default/files/files/documents/files/Report%20National%20Tuberculosis%20D.R.S%202006-2007.pdf

[5] The national tuberculosis drug resistance survey in Cambodia, 2000-2001 Yamada N, Saorith K, Yamakami K, Onozaki I, Boran S, Fujiki A, Eang MT, Mori T. Int J Tuberc Lung Dis. 2007 Dec;11(12):1321-7.

បាក់តេរីជាច្រើនប្រភេទ។[6] ភាពគ្មានផែនការជាតិគ្រប់ជ្រុងជ្រោយ និងយុទ្ធសាស្រ្តដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ, ការតាមដាននិងសមត្ថភាពមន្ទីរពិសោធន៍នៅខ្សោយការប្រើមិនសមស្របនូវភ្នាក់ងារប្រឆាំងមេរោគក្នុងពេលព្យាបាលជំងឺរបស់មនុស្សការប្រើអង់ទីប៊ីយ៉ូទិកច្រើនហួសហេតុជាកត្តាជំរុញការលូតលាស់នៅក្នុងកសិដ្ឋានចិញ្ចឹមសត្វ និងវិធានការបង្ការនិងត្រួតពិនិត្យការចម្លងរោគមានកម្រិតនៅក្នុងមន្ទីរពេទ្យគឺជាកត្តាដែលរួមចំណែកដល់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) នៅក្នុងប្រទេសកម្ពុជា។

ដើម្បីដោះស្រាយកង្វះខាតទាំងនេះ ការវិភាគស្ថានភាពក្នុងប្រទេសមួយត្រូវបានធ្វើឡើងនៅដើមឆ្នាំ២០១៣។ លទ្ធផលពីការវិភាគនេះ បានផ្តល់ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍគោលនយោបាយជាតិដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅក្នុងប្រទេសកម្ពុជានិងយុទ្ធសាស្រ្តជាតិដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅក្នុងប្រទេសកម្ពុជា។

[6] See Annex C, Country Situation Analysis of Antimicrobial Resistance in Cambodia, 2013.

# គោលការណ៍ណែនាំ

## គោលបំណង

គោលនយោបាយជាតិដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (NPCAR) គឺជាការប្តេជ្ញាចិត្តផ្នែកនយោបាយមួយ និងជាមគ្គុទ្ទេសក៍សម្រាប់សកម្មភាព ដែលផ្តល់សេចក្តីលម្អិតអំពីថាតើរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធដទៃទៀត គួរធ្វើការរួមគ្នាដូចម្តេចដើម្បីដោះស្រាយបញ្ហាដែលកំពុងតែកើនឡើងនៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) នៅក្នុងប្រទេស។ AMRគឺជាបញ្ហាដ៏សាំញ៉ាំមួយដែលបង្កឡើងដោយកត្តាពាក់ព័ន្ធគ្នាជាច្រើន ហើយគេត្រូវការសម្របសម្រួលក្នុងចំណោមភាគីពាក់ព័ន្ធនានាដើម្បីបញ្ឈប់បញ្ហានេះ។ NPCARកំណត់ពីតួនាទីនិងការទទួលខុសត្រូវរបស់វិស័យសាធារណៈ-ឯកជន និងសង្គមស៊ីវិលនិងផ្តល់ជាក្របខ័ណ្ឌទូទៅមួយសម្រាប់ណែនាំដល់ការសម្របសម្រួលសកម្មភាពក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់រួមទាំងវិស័យសាធារណៈនិងឯកជន អង្គការអប់រំនិងស្រាវជ្រាវ សមាគមវិជ្ជាជីវៈនិងភ្នាក់ងារផ្តល់ជំនួយ។

## ចក្ខុវិស័យ

សញ្ញាណប្រកបដោយផាសុខភាព ដោយមានការទទួលបានគ្រប់គ្រាន់នូវសេវាសុខាភិបាលប្រកបដោយ គុណភាពនិងឱសថប្រកបដោយប្រសិទ្ធភាព សំដៅទប់ស្កាត់ការកើតឡើង និងការរីករាលដាលនៃភាពស៊ាំទៅនឹងឱសថក្នុងចំណោមប្រជាជនកម្ពុជា។

## បេសកកម្ម

ដើម្បីធានាថាប្រទេសកម្ពុជាមានសមាសភាគសារវន្តដើម្បីទប់ស្កាត់ភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគរួមទាំងសមត្ថភាពនិងការតាមដានគុណភាពនិងការទទួលបានឱសថប្រឆាំងមេរោគសារវន្តការប្រើដោយសមស្របនិងប្រកបដោយការទទួលខុសត្រូវ ការបង្ការនិងការត្រួតពិនិត្យការចម្លង និងការស្រាវជ្រាវ និងការអភិវឌ្ឍនៃឧបករណ៍ថ្មីសម្រាប់ធ្វើរោគវិនិច្ឆ័យនិងការព្យាបាលជំងឺឆ្លង។

## វិសាលភាព

NPCAR កសាងបន្តពីរចនាសម្ព័ន្ធ និងគោលនយោបាយដែលមានស្រាប់នៅក្នុងប្រទេសដែលទាក់ទងដោយផ្ទាល់និងមិនផ្ទាល់ទៅនឹងភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ។ដោយសារ AMR គឺជាបញ្ហាអន្តរវិស័យ គោលនយោបាយនេះអនុវត្តចំពោះភាគីពាក់ព័ន្ធនានាដូចជា÷អ្នកតាក់តែងគោលនយោបាយ និងអ្នករៀបចំផែនការវិស័យសាធារណៈឯកជននិងអង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារផ្តល់ជំនួយអង្គការអប់រំនិងសមាគមវិជ្ជាជីវៈ វិស័យសុខភាពសត្វនិងមនុស្សអ្នកចេញវេជ្ជបញ្ជាអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលនិងអ្នកជំងឺ ឱសថការី និងអ្នកចែកថ្នាំនិងឧស្សាហកម្មឱសថ។

# គោលដៅ

## គោលដៅទូទៅនៃគោលនយោបាយ

គោលនយោបាយដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (NPCAR)ផ្តល់ទិសដៅទូទៅ និងក្របខ័ណ្ឌសម្រាប់ទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅគ្រប់កម្រិតថ្នាក់នៃប្រព័ន្ធថែទាំសុខភាព។ ដូច្នេះគោលនយោបាយនេះសង្កត់ធ្ងន់លើតួនាទីនិងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធទាំងអស់ និងបញ្ជាក់ពីគុណតម្លៃនិងគោលការណ៍ដើម្បីដោះស្រាយកត្តាដែលបង្កឲ្យមានភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅក្នុងប្រទេសកម្ពុជា។

## គោលដៅជាក់លាក់នៃគោលនយោបាយ

1. ស្វែងរកការគាំទ្រនិងកៀងគរធនធានដើម្បីគាំទ្រដល់សកម្មភាពនានាដើម្បីទប់ស្កាត់ AMR។
2. អប់រំភាគីពាក់ព័ន្ធសំខាន់ៗ និងសាធារណជនអំពីការកើតឡើងនិងការរីករាលដាលនៃ AMR និងកត្តានានាដែលបង្កឲ្យមានបញ្ហានេះនិងការចំណាយរបស់វា។
3. កំណត់ពីតួនាទីនិងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធផ្សេងៗនៅក្នុងការទប់ស្កាត់ AMR។
4. កែលម្អសមត្ថភាពមន្ទីរពិសោធន៍សម្រាប់រកឲ្យឃើញAMR និងប្រព័ន្ធតាមដានសម្រាប់តាមដានមើល AMR ។
5. ធានាការផ្គត់ផ្គង់ឱសថសារវន្តជាបន្តដែលមានធានាគុណភាព ដើម្បីគ្រប់គ្រងជំងឺឲ្យបានត្រឹមត្រូវនៅក្នុងមូលដ្ឋានសុខាភិបាល និងនៅក្នុងសហគមន៍។
6. សនិទានកម្មការប្រើប្រាស់ឱសថសារវ័ន្តដោយអ្នកផ្តល់សេវាថែទាំសុខភាព និងអ្នកជំងឺតាមរយៈការផ្តល់ព័ត៌មានដើម្បីកែលម្អការប្រើប្រាស់ឱសថ និងទិន្នន័យតាមដាន AMR។
7. ពង្រឹងការបង្កានិងត្រួតពិនិត្យការចម្លងរោគនៅក្នុងមូលដ្ឋានថែទាំសុខភាព និងសហគមន៍។
8. លើកកម្ពស់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ក្នុងវិស័យឱសថប្រឆាំងមេរោគនិងរោគវិនិច្ឆ័យ។
9. ពង្រឹងការសម្របសម្រួលនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាព និងការចែករំលែកចំណេះដឹងដើម្បីទប់ស្កាត់ AMR។
10. ជំរុញអភិបាលកិច្ចល្អនិងគណនេយ្យភាពដើម្បីគាំទ្រវិធានការជាអាទិភាពនៅក្នុងគោលនយោបាយនេះ។

# ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ក្របខ័ណ្ឌយុទ្ធសាស្ត្ររួមមានសមាសភាគចំនួនប្រាំមួយនៃកញ្ចប់គោលនយោបាយ ដើម្បីទប់ស្កាត់ AMRដែលបានបោះពុម្ពដោយអង្គការសុខភាពពិភពលោក (WHO) នៅក្នុងឆ្នាំ២០១១។ NPCARផ្តល់នូវដំណោះស្រាយដែលអាចអនុវត្តបានចំពោះបញ្ហា AMR ផ្អែកលើអ្វីដែលជាក់ស្តែងអាចដំណើរការទៅបានដោយជោគជ័យមានប្រសិទ្ធភាពមានលក្ខណៈរួមបញ្ចូលនិងអាចទទួលបានចំពោះអ្នកជំងឺ ស្ថាប័ន និងសហគមន៍។

ក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជាក់ពីគុណតម្លៃ និងគោលការណ៍ដែលថា ភាគីពាក់ព័ន្ធទាំងអស់ ត្រូវតែចូលរួមនិងសហប្រតិបត្តិការ ដើម្បីដោះស្រាយបញ្ហាភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគនៅក្នុងប្រទេសកម្ពុជា។នៅក្នុងក្របខ័ណ្ឌនេះ ក្រសួងសុខាភិបាលបានដាក់ចេញនូវសមាសភាគចំនួន៦សម្រាប់ធានានូវសកម្មភាពដែលផ្តោតចំគោលដៅនិងមាននិរន្តរភាពដែលអនុវត្តដោយវិស័យសុខភាពមនុស្ស និងសត្វ អង្គការក្រៅរដ្ឋាភិបាលសមាគមវិជ្ជាជីវៈដៃគូផ្តល់ជំនួយ សហគមន៍អ្នកជំងឺ និងវិស័យពាក់ព័ន្ធដទៃទៀត។សកម្មភាពទាំងនេះរួមមានដូចខាងក្រោម÷

1. រៀបចំផែនការជាតិគ្រប់ជ្រុងជ្រោយមួយ។
2. ពង្រឹងសមត្ថភាពតាមដាននិងមន្ទីរពិសោធន៍។
3. ធានាការទទួលបានប្រកបដោយនិរន្តរភាពនៃឱសថសារវន្តដែលមានគុណភាព។
4. និយ័តកម្មនិងលើកកម្ពស់ការប្រើឱសថដោយសមស្រប។
5. លើកកម្ពស់ការបង្ការនិងត្រួតពិនិត្យការចម្លងរោគ។
6. ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍន៍សំរាប់រកឧបករណ៍ថ្មី។

## 1. រៀបចំផែនការជាតិគ្រប់គ្រងជ្រោយ

ដោយសារកត្តាដែលជំរុញដល់ការកើតឡើងនិងការរីករាលដាននៃភាពស៊ាំរបស់មេរោគក៏ដូចជាវិធានការដែលត្រូវការដើម្បីទប់ស្កាត់ AMR ត្រូវបានគេដឹងយ៉ាងច្បាស់នោះនឹងមានផែនការគ្រប់គ្រងជ្រោយមួយដែលរៀបរាប់អំពីតួនាទី និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធនិងធនធានគ្រប់គ្រាន់ដើម្បីទប់ស្កាត់AMR។

*ក. ការសម្របសម្រួលកម្មវិធីជាតិដើម្បីទប់ស្កាត់ AMR ដោយរដ្ឋាភិបាល*

### *វចនាសម្ព័ន្ធនិងសមាសភាពនៃក្រុមការងារទប់ស្កាត់ភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ*

1. ក្រុមការងារទប់ស្កាត់ភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគមួយ (AMR WG) ត្រូវបានបង្កើតឡើង និងមានសមាសភាពមកពីភាគីពាក់ព័ន្ធនានាដែលមានចំណេះដឹងអំពី AMR ឬអ្នកដែលធ្វើការដែលទាក់ទងដោយដោយផ្ទាល់ទៅនឹង AMR។
2. ក្រុមការងារ AMR WG នេះនឹងពង្រីកសមាជិករបស់ខ្លួនដើម្បីដាក់បញ្ចូលវិស័យផ្សេងៗដែលមានសកម្មភាពពាក់ព័ន្ធនឹង AMR។វិស័យទាំងនេះរួមមានសាធារណៈឯកជនអង្គការក្រៅរដ្ឋាភិបាលភ្នាក់ងារផ្តល់ជំនួយអង្គការអប់រំនិងការស្រាវជ្រាវ សមាគមវិជ្ជាជីវៈវិស័យសុខភាពមនុស្សនិងសត្វអ្នកចេញវេជ្ជបញ្ជាអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលនិងអ្នកជំងឺឱសថការីនិងអ្នកចែកថ្នាំនិងឧស្សាហកម្មឱសថ។
3. ក្រុមការងារ AMR WG នឹងត្រូវបានពង្រឹងផ្អែកតាមលក្ខខណ្ឌប្រតិបត្តិ និងការពិពណ៌នាអំពីតួនាទីនិងការទទួលខុសត្រូវរបស់សមាជិករបស់ខ្លួន។ការចូលរួមពីមន្ត្រីរដ្ឋាភិបាលសំខាន់ៗមកពីវិស័យផ្សេងៗនឹងធានាការសម្របសម្រួលអន្តរវិស័យព្រមទាំងលើកកម្ពស់ការយល់ដឹងអំពីបញ្ហា AMR នៅក្នុងរបៀបវារៈរបស់រដ្ឋាភិបាល។
4. ក្រុមការងារ AMR WG នឹងត្រូវបានសម្របសម្រួលដោយក្រសួងសុខាភិបាល តាមរយៈលេខាធិការដ្ឋានមួយ ដែលមានធនធាន ជំនាញនិងសិទ្ធិអំណាចដែលត្រូវការដើម្បីសម្របសម្រួលសកម្មភាពនៅទូទាំងរដ្ឋាភិបាល។
5. ក្រុមការងារ AMR WG នឹងជំរុញការចូលរួមយ៉ាងសកម្មពីម្ចាស់ជំនួយនិងដៃគូអភិវឌ្ឍន៍ដើម្បីធានាថាស្ថាប័នទាំងនេះបានទទួលព័ត៌មានអំពីភាពបន្ទាន់នៃបញ្ហា AMR និងទទួលបានការគាំទ្រពីពួកគេដើម្បីអនុវត្តសកម្មភាព AMR ។

6. ក្រុមការងារ AMR WG នឹងពង្រីកសមាជិកភាពរបស់ខ្លួនដើម្បីដាក់បញ្ចូលក្រសួងអប់រំនិងគណៈវិជ្ជាជីវៈក្នុងគោលបំណងធានាថា រាល់គោលនយោបាយនិងកម្មវិធីទាំងអស់ដែលផ្តោតលើការទប់ស្កាត់ AMR ត្រូវបានផ្សព្វផ្សាយតាមរយៈកម្មវិធីបណ្តុះបណ្តាលក្នុងប្រព័ន្ធ ហើយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលគោរពតាមបទប្បញ្ញត្តិដើម្បីទប់ស្កាត់AMR ដូចមានបញ្ជាក់នៅក្នុងគោលនយោបាយនេះស្រាប់។

*អាណត្តិរបស់ក្រុមការងារទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ*

1. សម្របសម្រួលកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិដើម្បីទប់ស្កាត់ AMR នៅក្នុងប្រទេសកម្ពុជា។
2. បង្កើតផែនការយុទ្ធសាស្រ្តជាតិមួយដើម្បីទប់ស្កាត់ AMR ផ្អែកលើAMR CSA និងNPCAR។
3. បង្កើតក្របខ័ណ្ឌត្រួតពិនិត្យតាមដានមួយដែលមានធាតុចេញជាក់លាក់និងសូចនាករអាចវាស់វែងបានដើម្បីត្រួតពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្រ្តទប់ស្កាត់ AMR។ក្រុមការងារAMR WG គួរតែរាយការណ៍ប្រចាំឆ្នាំអំពីសូចនាករទាំងនេះ។
4. ស្វែងរកការគាំទ្រសម្រាប់ការដាក់បញ្ចូលសកម្មភាពជាអាទិភាពដើម្បីទប់ស្កាត់AMR ទៅក្នុងផែនការវិស័យសុខាភិបាលជាតិនិងផែនការរបស់វិស័យពាក់ព័ន្ធដទៃទៀត។
5. ធានាបែងចែកធនធានគ្រប់គ្រាន់សម្រាប់អនុវត្តសកម្មភាពទប់ស្កាត់ AMR និងការកសាងសមត្ថភាពនៅគ្រប់គម្រិតថ្នាក់នៃវិស័យសុខាភិបាល និងវិស័យដែលពាក់ព័ន្ធដទៃទៀត។
6. ផ្សព្វផ្សាយអំពីបញ្ហា AMR ដោយគាំទ្រដល់យុទ្ធនាការអប់រំដែលផ្តោតលើសាធារណជនទូទៅអ្នកប្រកបវិជ្ជាជីវៈថែទាំសុខភាពដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធដទៃទៀត។

*ប្រតិបត្តិការរបស់ក្រុមការងារ AMR*

1. ក្រុមការងារ AMR WG ត្រូវជួបប្រជុំជាទៀងទាត់ដើម្បីសម្របសម្រួលការពិភាក្សាអំពីបញ្ហានានាដែលទាក់ទងនឹង AMR។
2. លេខាធិការដ្ឋានត្រូវធ្វើកំណត់ហេតុ ចែកចាយក្នុងចំណោមសមាជិករបស់ខ្លួននិងរក្សាទុកសម្រាប់ជាឯកសារយោងក្នុងពេលអនាគត។

3. ក្រុមការងារ AMR WG នឹងបង្កើតក្រមប្រតិបត្តិមួយ (code of conduct) ដែលចែងពីគោលការណ៍គ្រប់គ្រងភាពសម្ងាត់ភាពមិនលំអៀងនិងតម្លាភាពនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តព្រមទាំងរួមបញ្ចូលនូវយន្តការមួយសម្រាប់ដោះស្រាយជម្លោះខាងផលប្រយោជន៍ ក្នុងចំណោមសមាជិករបស់ខ្លួន។
4. ក្រុមការងារ AMR WG ត្រូវពិនិត្យឡើងវិញនូវសមាសភាពរបស់ខ្លួនជារៀងរាល់ឆ្នាំ ដើម្បីធានាភាពជាតំណាងមកពីគ្រប់វិស័យ និងភាគីពាក់ព័ន្ធ។

*ខ. គម្រោងថវិកាចំណាយសម្រាប់ផែនការនិងការកៀងគរធនធាន*

***ការរៀបចំគម្រោងថវិកានិងការកៀងគរធនធាន***

1. ក្រុមការងារ AMR WG ត្រូវប៉ាន់ស្មានថវិកាដែលត្រូវការដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់ទប់ស្កាត់AMR និងស្វែងរកការគាំទ្រពីថវិកាជាតិនិងថវិកាខាងក្រៅ។
2. ក្រុមការងារ AMR WG ត្រូវកៀងគរធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីគាំទ្រការអនុវត្តផែនការ តាមរយៈការវិភាជន៍ថវិកាជាទៀងទាត់ការកែតម្រូវសកម្មភាពនៅក្នុងសមាសភាគកម្មវិធីស្នូលនិងនៅក្នុងគំនិតផ្តួចផ្តើមសុខភាពជាអាទិភាពដទៃទៀត។

*គ. កសាងភាពជាដៃគូជាមួយសង្គមស៊ីវិល*

***ការចូលរួមជាផ្លូវការនៅក្នុងការងារ AMR***

1. ក្រុមការងារ AMR WG ត្រូវពង្រីកសមាជិករបស់ខ្លួនដើម្បីដាក់បញ្ចូលតំណាងមកពីសង្គមស៊ីវិល។
2. តំណាងមកពីសង្គមស៊ីវិល គួរចូលរួមជាផ្លូវការនៅក្នុងសង្គមភាពទប់ស្កាត់AMR រួមទាំងការអភិវឌ្ឍគោលនយោបាយនិងផែនការយុទ្ធសាស្ត្រដែលទាក់ទងនឹង AMR ព្រមទាំងចូលរួមនៅក្នុងការត្រួតពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីនិងសកម្មភាពដែលពាក់ព័ន្ធ។

***ការផ្តល់សិទ្ធិអំណាចសម្រាប់ការចូលរួមកាន់តែសកម្ម***

1. ក្រុមការងារ AMR WG ត្រូវរៀបចំកិច្ចប្រជុំសាធារណៈជាទៀងទាត់ដើម្បីពិភាក្សាអំពីបញ្ហា AMR។

2. ផ្តល់ការអប់រំដល់អតិថិជនអំពី AMR និងការប្រើឱសថប្រឆាំងមេរោគ ដោយសហការជាមួយភាគីពាក់ព័ន្ធដោយសង្កត់ធ្ងន់លើអត្ថប្រយោជន៍នៃការប្រើឱសថសមស្រប និងការគោរពតាមមគ្គុទ្ទេសក៍និងបទប្បញ្ញត្តិស្តីពីការព្យាបាលដោយឱសថប្រឆាំងមេរោគ។
3. អភិវឌ្ឍសមត្ថភាពអង្គការសង្គមស៊ីវិល សំដៅរួមចំណែកដល់ការអនុវត្តសកម្មភាពនៅក្នុងផែនការយុទ្ធសាស្រ្តជាតិដើម្បីទប់ស្កាត់ AMR។

## 2. ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ដើម្បីវិភាគរក AMR

*ក. កសាងសមត្ថភាពសម្រាប់ការធ្វើរោគវិនិច្ឆ័យបានឆាប់រហ័សនិងអាចជឿទុកចិត្តបាន*

*សមត្ថភាពនិងបណ្តាញមន្ទីរពិសោធន៍សម្រាប់ រកAMR*

1. ក្រសួងសុខាភិបាល ត្រូវពង្រឹងគុណភាពមន្ទីរពិសោធន៍សាធារណៈនិងធានាឲ្យបាននូវគុណភាពរបស់មន្ទីរពិសោធន៍ឯកជននិងអង្គការក្រៅរដ្ឋាភិបាល។
2. ក្រសួងសុខាភិបាលត្រូវចាត់តាំងមន្ទីរពិសោធន៍មីក្រូជីវសាស្រ្តមួយជាមន្ទីរពិសោធន៍បង្អែកក្នុងការធ្វើការវិភាគរក AMR តាមបច្ចេកទេសដែលមន្ទីរពិសោធន៍តូចៗទាំងនោះគ្មាន( ដើម្បីទទួលយកឧទា. បច្ចេកទេសម៉ូលេគុល)។
3. ក្រសួងសុខាភិបាលត្រូវបង្កើតបណ្តាញមន្ទីរពិសោធន៍មីក្រូជីវសាស្រ្តជាតិមួយដែលរួមបញ្ចូលទាំងមន្ទីរពិសោធន៍សាធារណៈ ឯកជន និងអង្គការក្រៅរដ្ឋាភិបាល ដែលរួមចំណែកផ្តល់ទិន្នន័យស្តីពី AMR ដល់ប្រព័ន្ធទិន្នន័យជាតិ។
4. ក្រសួងសុខាភិបាលត្រូវដាក់បញ្ចូលសមត្ថភាពរក AMR ជាផ្នែកមួយនៃបណ្តាញមន្ទីរពិសោធន៍ថ្នាក់ជាតិ។

*ការគ្រប់គ្រងនិងការប្រើប្រាស់នៃទិន្នន័យមន្ទីរពិសោធន៍*

1. មន្ទីរពិសោធន៍មីក្រូជីវសាស្រ្ត ត្រូវអនុវត្តវិធីសាស្រ្តស្តង់ដាររួមសម្រាប់ធ្វើការកំណត់រកអត្តសញ្ញាណមេរោគ និងការវិភាគរកប្រសិទ្ធភាពឱសថប្រឆាំងមេរោគ (AST)។

2. ក្រសួងសុខាភិបាលត្រូវធានានិរន្តរភាពនៃការផ្គត់ផ្គង់ប្រតិករនិងសម្ភារៈផ្សេងៗសម្រាប់ប្រើប្រាស់នៅក្នុងមន្ទីរពិសោធន៍ប្រកបដោយគុណភាព។
3. គ្រប់មន្ទីរពិសោធន៍ត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងគុណភាពដើម្បីធានាបានភាពអាចជឿទុកចិត្តបាននៃលទ្ធផលមន្ទីរពិសោធន៍។
4. មន្ទីរពិសោធន៍ត្រូវកត់ត្រា និងរាយការណ៍នូវទិន្នន័យស្តីអំពី AMR ភ្លាមៗ ដល់អ្នកចេញវេជ្ជបញ្ជា ដល់កម្មវិធីត្រួតពិនិត្យការចម្លងរោគនិងអាជ្ញាធរសុខាភិបាលជាតិ។
5. ក្រសួងសុខាភិបាល ត្រូវបង្កើតគោលការណ៍ណែនាំសម្រាប់ការទាក់ទង ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការប្រើប្រាស់លទ្ធផលវិភាគ AMR របស់មន្ទីរពិសោធន៍ នៅក្នុងការគ្រប់គ្រងផ្នែកគ្លីនិក។

## 3. ពង្រឹងការតាមដាន AMR

### *ក. បង្កើតប្រព័ន្ធតាមដាននិងត្រួតពិនិត្យ AMR*

#### ***ដំណើរការនិងវិធីសាស្ត្រ***

1. បង្កើតពិធីសារស្តង់ដារជាតិ ដើម្បីវាយតម្លៃស្ថានភាពនៃ AMR ជាប់ជាប្រចាំ និងនៅទូទាំងប្រទេស ព្រមទាំងពង្រឹងការតាមដាន AMR ដោយប្រើវិធីសាស្ត្រអេពីដេមីសាស្ត្រសមស្រប។
2. បង្កើតប្រព័ន្ធមួយដើម្បីផ្ទេរទិន្នន័យពីមន្ទីរពេទ្យ និងមូលដ្ឋានសុខាភិបាលដទៃទៀត ទៅថ្នាក់ជាតិក្នុងគោលបំណងដើម្បីផ្សារភ្ជាប់លទ្ធផលមន្ទីរពិសោធន៍ ជាមួយព័ត៌មានគ្លីនិក។
3. បង្កើតប្រព័ន្ធមួយសម្រាប់កត់ត្រាការប្រើឱសថប្រឆាំងមេរោគនៅក្នុងគ្រប់មូលដ្ឋានសុខាភិបាល។
4. បង្កើតយន្តការមួយដើម្បីដាក់បញ្ចូលប្រព័ន្ធសម្រាប់តាមដាន AMR រវាងសេវាសុខភាពសាធារណៈ សេវាពេទ្យសត្វ និងអាជ្ញាធរសុវត្ថិភាពចំណីអាហារ។

#### ***ការគ្រប់គ្រងទិន្នន័យតាមដាន***

1. ទិន្នន័យតាមដានAMR នឹងត្រូវបានដាក់បញ្ចូលគ្នាវិភាគនិងរាយការណ៍ជាទៀងទាត់ដោយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង។

2. របាយការណ៍តាមដាន AMR នឹងត្រូវបានប្រើប្រាស់ដើម្បីជាមូលដ្ឋានសម្រាប់ការកែសម្រួលគោលការណ៍ណែនាំស្ដីពីការអនុវត្តគ្លីនិកនិងបញ្ជីឱសថសារវន្ត។
3. ប្រព័ន្ធគ្រប់គ្រងគុណភាពមួយនឹងត្រូវបានបង្កើតឡើងដែលរួមបញ្ចូលការត្រួតពិនិត្យតាមដាននិងអភិបាលមន្ទីរពិសោធន៍មីក្រូជីវសាស្ត្រ ដែលរាយការណ៍អំពីទិន្នន័យ AMR ការបណ្តុះបណ្តាលបន្តដល់បុគ្គលិកនិងការវាយតម្លៃទិន្នន័យ AMR ដែលបានប្រមូល។
4. យន្តការរាយការណ៍និងការផ្សព្វផ្សាយស្តង់ដារនៃព័ត៌មាន ស្តីពី AMR នឹងត្រូវបានបង្កើតឡើង និងពង្រឹងអនុវត្ត។

*ការចូលរួមនៅក្នុងការតាមដានអន្តរជាតិ*

1. ក្រុមការងារ AMR WG ត្រូវចែករំលែកទិន្នន័យតាមដានថ្នាក់ជាតិអំពី AMR និងការប្រើឱសថប្រឆាំងមេរោគជាមួយអង្គការសុខភាពពិភពលោកនិងអង្គការអន្តរជាតិដទៃទៀត។
2. ក្រសួងសុខាភិបាល MoH ត្រូវតែងតាំងមន្ទីរពិសោធន៍បង្អែកថ្នាក់ជាតិមួយសម្រាប់ AMR ។
3. ក្រុមការងារ AMR WG ត្រូវគាំទ្រដល់មន្ទីរពិសោធន៍បង្អែកជាតិសម្រាប់ AMR ដើម្បីចូលរួមនៅក្នុងបណ្តាញមន្ទីរពិសោធន៍ថ្នាក់តំបន់ដែលពាក់ព័ន្ធនៅក្នុងការតាមដាន AMR ។

## 4. ធានាការទទួលបានឱសថប្រឆាំងមេរោគប្រកបដោយគុណភាព

*ក. ពង្រឹងប្រព័ន្ធផ្គត់ផ្គង់ឱសថសារវន្តប្រឆាំងមេរោគ*

*ការគ្រប់គ្រងការផ្គត់ផ្គង់ឱសថប្រឆាំងមេរោគ*

1. គណៈកម្មការឱសថសារវន្តត្រូវតែងតាំងអនុគណៈកម្មការមួយដើម្បីសម្របសម្រួលការបង្កើតនិងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវបញ្ជីឱសថសារវន្តប្រឆាំងមេរោគដែលជាផ្នែកមួយនៃបញ្ជីឱសថសារវន្ត។
2. ក្រសួងសុខាភិបាលត្រូវបង្កើតយន្តការព្យាករណ៍សម្រាប់ការប្រើប្រាស់និងការចំណាយលើឱសថប្រឆាំងមេរោគ។

3. ក្រសួងសុខាភិបាលពង្រឹងប្រព័ន្ធលទ្ធកម្មនិងផ្គត់ផ្គង់សម្រាប់ឱសថប្រឆាំងមេរោគ។
4. ក្រសួងសុខាភិបាលត្រូវបង្កើតនិងអនុវត្តយន្តការនានាដើម្បីធានាគុណភាពរបស់ឱសថប្រឆាំងមេរោគ រួមជាមួយសង្វាក់ផ្គត់ផ្គង់។

*តម្លៃសមរម្យនិងហិរញ្ញប្បទានប្រកបដោយនិរន្តរភាព*

1. មាត្រានៃបទប្បញ្ញត្តិរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ស្តីពីទិដ្ឋភាពដែលទាក់ទងនឹងពាណិជ្ជកម្មនៃកម្មសិទ្ធិបញ្ញា (TRIPS) រួមទាំងការចេញអាជ្ញាប័ណ្ណបញ្ចូសម្រាប់ឱសថ នឹងត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិ។
2. គោលនយោបាយកំណត់តម្លៃដែលនឹងធានាការទទួលបានឱសថប្រឆាំងមេរោគរួមទាំងការលើកលែងអាករលើតម្លៃបន្ថែម (VAT) នឹងត្រូវបានរៀបចំឡើងដោយសហការជាមួយអាជ្ញាធរដែលពាក់ព័ន្ធនៅក្នុងកិច្ចការហិរញ្ញវត្ថុ ការធ្វើអាជីវកម្ម និងពាណិជ្ជកម្មគោលបំណងដើម្បីធានាថាតម្លៃមិនមែនជាឧបសគ្គដែលត្រូវប្រកាន់ខ្ជាប់ដោយពេញលេញទៅនឹងការព្យាបាលដោយឱសថប្រឆាំងមេរោគនោះឡើយ។
3. យន្តការត្រួតពិនិត្យតាមដានតម្លៃសម្រាប់ឱសថប្រឆាំងមេរោគ គួរត្រូវបានបង្កើតឡើងដោយមានការចូលរួមយ៉ាងសកម្មពីអ្នកប្រើប្រាស់ និងភាគីពាក់ព័ន្ធ។
4. យន្តការនឹងត្រូវបានបង្កើតឡើងដើម្បីវិភាគហិរញ្ញប្បទានសម្រាប់ឱសថប្រឆាំងមេរោគនិងត្រួតពិនិត្យការចំណាយដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៅក្នុងការប្រើប្រាស់និងការផ្គត់ផ្គង់ឱសថប្រឆាំងមេរោគ។
5. មូលនិធិសមធម៌សុខភាពនឹងគ្របដណ្តប់លើឱសថប្រឆាំងមេរោគផងដែរ។

*ខ. ធានាគុណភាពឱសថយោងតាមស្តង់ដារដែលអាចទទួលយកបាន*

*បរិយាកាសនិងដំណើរការនិយតកម្ម*

1. នាយកដ្ឋានឱសថចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសំអាង (DDF) ដែលមានតួនាទីជាអាជ្ញាធរនិយ័តកម្មឱសថជាតិនឹងត្រូវបានពង្រឹងដើម្បីទទួលខុសត្រូវលើគ្រប់ទិដ្ឋភាពទាំងអស់នៃនិយតកម្មឱសថ។
2. គណៈកម្មាធិការអន្តរក្រសួងទប់ស្កាត់ឱសថស្ថានខុសច្បាប់និងការលក់ឱសថខុសច្បាប់នឹងត្រូវបានពង្រឹង។

3. យន្តការសម្រាប់ប្រព័ន្ធត្រួតពិនិត្យតាមដានដំណើរការនិយតកម្មនឹងត្រូវបានបង្កើតឡើង។
4. រៀបចំបង្កើតនិងពង្រឹងយន្តការតាមដានឱសថអង់ទីប៊ីយ៉ូទិកនិងឱសថប្រឆាំងមេរោគក្រោយពេលដាក់លក់លើទីផ្សារ។
5. ត្រួតពិនិត្យនិងទប់ស្កាត់ការផ្សាយពាណិជ្ជកម្មនិងការផ្សព្វផ្សាយអំពីឱសថប្រឆាំងមេរោគ។

## 5. និយតកម្មនិងលើកកម្ពស់ការប្រើឱសថដោយសមស្រប

*ក. លើកកម្ពស់ និងពង្រឹងមគ្គុទ្ទេសក៍ព្យាបាលស្តង់ដារ*

### *មគ្គុទ្ទេសក៍ស្តីពីការអនុវត្តគ្លីនិកនិងបញ្ជីឱសថសារវន្ត*

1. មគ្គុទ្ទេសក៍ស្តីពីការអនុវត្តគ្លីនិកនឹងត្រូវបានបង្កើតឡើងដោយមានការចូលរួមពីពហុជំនាញនិងប្រកបដោយតម្លាភាពព្រមទាំងធ្វើបច្ចុប្បន្នភាពដោយផ្អែកលើភ័ស្តុតាងក្នុងស្រុកនិងអន្តរជាតិនិងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដោយសហការជាមួយអង្គការវិជ្ជាជីវៈនិងគ្រឹះស្ថានអប់រំដើម្បីផ្តល់ជាមគ្គុទ្ទេសក៍បឋមមួយនៅក្នុងការផ្តល់សេវាសុខភាពដល់អ្នកជំងឺ។
2. បច្ចុប្បន្ននេះ មគ្គុទ្ទេសក៍ស្តីពីការអនុវត្តគ្លីនិកត្រូវតែជាផ្នែកមួយនៃកម្មវិធីសិក្សានិងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់និស្សិតនិងបុគ្គលិកថែទាំសុខភាព។
3. បញ្ជីឱសថសារវន្តត្រូវមានឱសថដែលបំពេញតាមតម្រូវការផ្នែកការថែទាំសុខភាពរបស់ប្រជាពលរដ្ឋនិងអាចរកបានគ្រប់ពេលក្នុងបរិមាណគ្រប់គ្រាន់និងក្នុងទម្រង់កម្រិតប្រើសមស្របព្រមទាំងក្នុងតម្លៃមួយដែលសហគមន៍មានលទ្ធផលទិញបាន។សម្រាប់ជំងឺទាំងឡាយដែលពុំមានមគ្គុទ្ទេសក៍ព្យាបាលជាតិយន្តការដែលផ្អែកលើភ័ស្តុតាងនិងមានតម្លាភាពមួយនឹងត្រូវបានបង្កើតឡើង ដើម្បីដាក់បញ្ចូលឱសថទៅក្នុងបញ្ជីឱសថសារវន្ត។
4. មគ្គុទ្ទេសក៍ស្តីពីការអនុវត្តគ្លីនិក ត្រូវតែផ្តល់ជាមូលដ្ឋានសម្រាប់ការដាក់បញ្ចូល/ការដកចេញនូវឱសថណាមួយនៅក្នុងបញ្ជីឱសថសារវន្ត។

5. បញ្ជីឱសថសារវ័ន្ត ត្រូវធ្វើការពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នកម្មជាទៀងទាត់។ បញ្ជីឱសថសារវ័ន្តបច្ចុប្បន្ន នឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋាននៃការជ្រើសរើស និងលទ្ធកម្មនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ។

*គណៈកម្មាធិការព្យាបាលដោយឱសថ*

1. មន្ទីរពេទ្យសាធារណៈទាំងអស់ត្រូវបង្កើត និងពង្រឹងគណៈកម្មាធិការព្យាបាលដោយឱសថ ដែលមានតួនាទីនិងមុខងារច្បាស់លាស់។
2. គណៈកម្មាធិការព្យាបាលដោយឱសថយ៉ាងហោចណាស់ត្រូវចូលរួមដោយសកម្មនៅក្នុង÷
    a. ជំរុញការចេញវេជ្ជបញ្ជាដោយសមស្របចែកនិងប្រើប្រាស់ឱសថប្រឆាំងមេរោគ ដោយធានាថាអ្នកផ្តល់សេវាសុខភាពនិងអ្នកជំងឺអនុវត្តតាមស្តង់ដារនិងមគ្គុទ្ទេសក៍ស្តីពីការប្រើឱសថដោយសមស្រប។
    b. រៀបចំសៀវភៅមគ្គុទ្ទេសក៍ឱសថសម្រាប់មន្ទីរពេទ្យ ស្របតាមមគ្គុទ្ទេសក៍ស្តីពីការអនុវត្តគ្លីនិកនិងបញ្ជីឱសថសារវ័ន្ត។
    c. កែសម្រួលការបញ្ជាទិញឱសថប្រឆាំងមេរោគដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពមានជំងឺនិងមរណភាពបច្ចុប្បន្នរួមទាំងលំនាំនៃAMR។
    d. ធ្វើការត្រួតពិនិត្យតាមដាននិងរាយការណ៍អំពីហេតុការណ៍នានាដែលទាក់ទងប្រតិកម្មឱសថនិងប្រឆាំងមេរោគនិងឱសថប្រឆាំងមេរោគដែលគ្មានប្រសិទ្ធភាព/ក្លែងក្លាយ/អន់គុណភាព។

*ការចេញអាជ្ញាប័ណ្ណនិងការត្រួតពិនិត្យតាមដាន*

1. អនុវត្តគម្រោងចេញអាជ្ញាប័ណ្ណនិងត្រួតពិនិត្យតាមដានដ៏តឹងរឹងមួយសម្រាប់ឱសថស្ថាននិងកន្លែងលក់ឱសថដទៃទៀតដើម្បីធានាថាឱសថប្រឆាំងមេរោគត្រូវបានចែកជូនអតិថិជនដែលមានវេជ្ជបញ្ជាដែលមានសុពលភាពតែប៉ុណ្ណោះ។

2. ហាមឃាត់ការចេញវេជ្ជបញ្ជានិងការលក់ឱសថតែមួយមុខសម្រាប់ព្យាបាលជំងឺក្នុងករណីនានាដែលការព្យាបាលត្រូវបានណែនាំឲ្យប្រើឱសថច្រើនមុខរួមបញ្ចូលគ្នា។

*ខ. ដាក់បញ្ចូលជាផ្លូវការកម្មវិធីដឹកនាំឱសថប្រឆាំងមេរោគ ទៅក្នុងមូលដ្ឋានសុខាភិបាល*

***សកម្មភាពដឹកនាំឱសថប្រឆាំងមេរោគ***

1. មន្ទីរពេទ្យទាំងអស់ត្រូវរៀបចំបង្កើតក្រុមការងារដឹកនាំឱសថប្រឆាំងមេរោគដែលមានជំនាញចម្រុះដែលរួមមានវេជ្ជបណ្ឌិតឱសថការីអ្នកបច្ចេកទេសមន្ទីរពិសោធន៍អ្នកឯកទេសខាងជំងឺឆ្លងនិងគិលានុបដ្ឋាកដើម្បីសម្របសម្រួលយុទ្ធសាស្ត្រកែលម្អការប្រើឱសថប្រឆាំងមេរោគនៅក្នុងមូលដ្ឋានសុខាភិបាល។
2. បង្កើតយន្តការសម្រាប់ណែនាំឲ្យដាក់បញ្ចូលទៅក្នុងសៀវភៅមគ្គុទ្ទេសក៏ឱសថរបស់មន្ទីរពេទ្យ នូវឱសថប្រឆាំងមេរោគដែលមិនត្រួតគ្នា (non-duplicative antimicrobials) ដែលមានតម្រូវការផ្នែកគ្លីនិកច្បាស់លាស់។
3. អភិវឌ្ឍវិធីព្យាបាលជាក់ស្តែងសម្រាប់គ្រប់គ្រងចង្កោមរោគសញ្ញាឆ្លងជំងឺទូទៅនិងការបង្ការដោយប្រើឱសថសម្លាប់មេរោគ (អង់ទីប៊ីយ៉ូទិក)ដោយផ្អែកលើអង់ទីប៊ីយ៉ូក្រាមនៅក្នុងស្រុកនិងមគ្គុទ្ទេសក៍ស្តីពីការអនុវត្តគ្លីនិក (CPG)។
4. បង្កើតយន្តការដើម្បីធានានិងតាមដានការប្រើឱសថប្រឆាំងមេរោគនៅថ្នាក់ស្ថាប័ន។
5. ការបែងចែកជាទៀងទាត់ នូវអត្រាប្រសិទ្ធភាពឱសថអង់ទីប៊ីយ៉ូទិកសម្រាប់មេរោគសំខាន់ៗនៅក្នុងមន្ទីរពេទ្យដែលមានមន្ទីរពិសោធន៍មីក្រូជីវសាស្ត្រនឹងជួយណែនាំដល់ការគ្រប់គ្រងផ្នែកគ្លីនិក។

*គ. លើកកម្ពស់ការអប់រំអំពីឱសថប្រឆាំងមេរោគ និងការប្រើឱសថទាំងនេះឲ្យបានត្រឹមត្រូវ។*

***ការផ្តល់ព័ត៌មានអំពីឱសថ***

1. ក្រសួងសុខាភិបាលត្រូវផ្តល់ព័ត៌មានដោយឯករាជ្យ និងមិនលំអៀងអំពីឱសថសម្រាប់អ្នកផ្តល់សេវា និងអ្នកប្រើប្រាស់។
2. ធ្វើយុទ្ធនាការអប់រំសុខភាពដល់សាធារណជនឲ្យបានទៀងទាត់។

3. ដាក់បញ្ចូលការប្រើប្រាស់ឱសថសមស្របទៅក្នុងកម្មសិក្សាតាមសាលានិងកម្មវិធីអប់រំមនុស្សពេញវ័យ។
4. លើកទឹកចិត្តអ្នកជំងឺនិងអ្នកប្រើប្រាស់ ឲ្យចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពអប់រំផ្សព្វផ្សាយ។
5. ធ្វើយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ។

*ការអភិវឌ្ឍវិជ្ជាជីវៈនិងការអប់រំបន្ត*

1. មន្ទីរពេទ្យនិងមូលដ្ឋានសុខាភិបាលដទៃទៀតត្រូវផ្តល់ការបណ្តុះបណ្តាល និងការអប់រំបន្តដល់បុគ្គលិករបស់ខ្លួនជាពិសេសនៅក្នុងផ្នែកឱសថប្រឆាំងមេរោគ និង AMR ។
2. ការចេញអាជ្ញាប័ណ្ណ នឹងត្រូវផ្សារភ្ជាប់ទៅនឹងការចូលរួមជាទៀងទាត់នៅក្នុងសកម្មភាពអប់រំបន្ត។
3. សមាគមវិជ្ជាជីវៈនិងគ្រឹះស្ថានបណ្តុះបណ្តាលត្រូវផ្តល់ការបណ្តុះបណ្តាលដោយផ្អែកលើបញ្ហាជាក់ស្តែង (problem-based training) អំពីការប្រើឱសថសមស្របដោយផ្សារភ្ជាប់ទៅនឹងមគ្គុទ្ទេសក៍ស្តីពីការអនុវត្តគ្លីនិកនិងបញ្ជីឱសថសារវ័ន្ត។
4. បណ្តុះបណ្តាលអ្នកចេញវេជ្ជបញ្ជានិងអ្នកចែកថ្នាំដើម្បីអប់រំអ្នកជំងឺអំពីរបៀបប្រើឱសថប្រឆាំងមេរោគដោយត្រឹមត្រូវ និងសារៈសំខាន់នៃការគោរពតាមវេជ្ជបញ្ជាគ្រូពេទ្យឲ្យបានត្រឹមត្រូវ។

*ឃ. កាត់បន្ថយគ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដែលលើកទឹកចិត្តដល់ការប្រើឱសថដោយមិនសមស្រប*

*គ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ*

1. ធ្វើការវិភាគលើរចនាសម្ព័ន្ធលើកទឹកចិត្តដែលមានស្រាប់ដើម្បីកំណត់ពីកត្តានានាដែលមានឥទ្ធិពលលើរបៀបនៃការចេញវេជ្ជបញ្ជានិងចែកថ្នាំ ព្រមទាំងបង្កើតគោលនយោបាយដើម្បីកាត់បន្ថយគ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់អ្នកផ្តល់សេវា។
2. បែងចែកឲ្យដាច់ពីគ្នារវាងការចេញវេជ្ជបញ្ជានិងការចែកថ្នាំព្រមទាំងត្រួតពិនិត្យតាមដានសកម្មភាពនេះជាទៀងទាត់ដើម្បីធានាការគោរពតាមគោលការណ៍ជាធរមាន។

*ការផ្សព្វផ្សាយឱសថ*

1. ក្រុមហ៊ុនឱសថត្រូវធានាថារាល់សកម្មភាពផ្សព្វផ្សាយទាំងអស់បង្ហាញពីព័ត៌មានដែលពិត ផ្អែកលើភ័ស្តុតាង និងអនុលោមតាមគោលការណ៍ក្រមសីលធម៌ស្តីពីការផ្សព្វផ្សាយឱសថដែលមានស្រាប់ (របស់អង្គការសុខភាពពិភពលោកក្រសួងសុខាភិបាល)
2. ក្រសួងសុខាភិបាលត្រូវត្រួតពិនិត្យតាមដាននិងរាយការណ៍អំពីការផ្សព្វផ្សាយដោយអះអាងមិនពិត ព័ត៌មានមិនពិតនិងសកម្មភាពទាំងឡាយដែលមិនគោលរពតាមគោលការណ៍ក្រមសីលធម៌ស្តីពីការផ្សព្វផ្សាយឱសថនិងផលិតផលវេជ្ជសាស្រ្តដទៃទៀត)។
3. ពង្រឹងការអនុវត្តច្បាប់ ដើម្បីស៊ើបអង្កេតការចោទប្រកាន់ និងដាក់ទោសចំពោះការរំលោភច្បាប់។
4. ក្រសួងសុខាភិបាលត្រូវពង្រឹងដំណើរការនៃការអនុម័តលើសម្ភារៈ ដែលប្រើប្រាស់នៅក្នុងការផ្សាយពាណិជ្ជកម្មនិងផ្សព្វផ្សាយឱសថ។
5. ក្រសួងសុខាភិបាលត្រូវហាមឃាត់ការផ្សព្វផ្សាយឱសថប្រឆាំងមេរោគនៅក្នុងមន្ទីរពេទ្យ។

*ង. កាត់បន្ថយការប្រើឱសថប្រឆាំងមេរោគនៅក្នុងបសុសត្វ*

*សហប្រតិបត្តិការអន្តរវិស័យ*

1. បង្កើតយន្តការផ្លូវការមួយដើម្បីធ្វើឲ្យប្រសើរឡើងនូវការសម្របសម្រួលរវាងក្រសួងសុខាភិបាលក្រសួងកសិកម្មរុក្ខារប្រមាញ់ និងនេសាទសកលវិទ្យាល័យនិងកាំកុងត្រូល/ក្រសួងពាណិជ្ជកម្មដើម្បីដោះស្រាយបញ្ហា AMR នៅក្នុងវិស័យកសិកម្ម។
2. នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល និងនាយកដ្ឋានជលផល ត្រូវមានតំណាងនៅក្នុងក្រុមការងារ AMR WG។

*ក្របខ័ណ្ឌនិយតកម្មអំណោយ*

1. បង្កើតក្របខ័ណ្ឌនិយតកម្មសម្រាប់អនុញ្ញាតនិងត្រួតពិនិត្យគុណភាពនៃឱសថបសុសត្វ។

2. ដាក់ឱ្យអនុវត្តនូវការវាយតម្លៃមុនពេលផ្តល់អាជ្ញាប័ណ្ណនូវសុវត្ថិភាពឱសថប្រឆាំងមេរោគដែលប្រើប្រាស់សម្រាប់បសុសត្វ ដោយពិចារណាអំពីភាពស៊ាំដែលអាចមានកើតឡើងចំពោះឱសថដែលប្រើនៅក្នុងវេជ្ជសាស្ត្រមនុស្ស។
3. ហាមឃាត់ការប្រើឱសប្រឆាំងមេរោគដែលមិនមានគោលបំណងព្យាបាល ដូចជាការប្រើឱសថប្រឆាំងមេរោគ ជាសារធាតុជំរុញការលូតលាស់ជាដើម។
4. ហាមឃាត់និងលុបបំបាត់ជាដំណាក់កាលៗនូវការប្រើឱសថប្រឆាំងមេរោគសម្រាប់បសុសត្វ ដែលត្រូវបានកំណត់ថាសំខាន់បំផុតសម្រាប់វេជ្ជសាស្ត្រមនុស្សជាពិសេសផ្លុយអ័រូគីណូឡូន (fluoroquinolones) និងសេហ្វាឡូស្ពរីន (cephalosporins) ជំនាន់ទី៣និងទី៤។
5. ត្រូវមានវេជ្ជបញ្ជាសម្រាប់រាល់ឱសថប្រឆាំងមេរោគទាំងអស់ ដែលប្រើសម្រាប់ការប្រយុទ្ធនឹងជំងឺនៅក្នុងសបុសត្វ។

*ការតាមដាននិងការត្រួតពិនិត្យ*

1. បង្កើតប្រព័ន្ធជាតិមួយដើម្បីត្រួតពិនិត្យមើលការប្រើឱសថប្រឆាំងមេរោគនៅក្នុងបសុសត្វដោយផ្សារភ្ជាប់ទៅនឹងប្រព័ន្ធតាមដាន AMR នៅក្នុងវិស័យសុខភាពមនុស្ស។
2. បង្កើតកម្មវិធីតាមដានរួមបញ្ចូលគ្នាមួយដើម្បីត្រួតពិនិត្យមើលលំនាំនៃ AMR ដែលកំពុងលេចចេញឡើងក្នុងពេលបច្ចុប្បន្ន រួមទាំងទិន្នន័យ quantitativesusceptibility សម្រាប់មេរោគក្នុងសត្វ និងបាក់តេរីដែលជាសូចនាករ។
3. ការតាមដាននៅក្នុងវិស័យបសុសត្វ តម្រូវឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធរវាងមន្ត្រីមកពីមន្ទីរពិសោធន៍សុខភាពសាធារណៈបសុសត្វនិងចំណីអាហារ។
4. ក្រុមការងារ AMR WG ត្រូវវិភាគទិន្នន័យតាមដានសម្រាប់កំណត់ពីទំនោរ ការប៉ាន់ប្រមាណហានិភ័យនិងត្រួតពិនិត្យមើលឥទ្ធិពលនៃអន្តរាគមន៍។
5. ក្រុមការងារ AMR WG ត្រូវជំរុញការអភិវឌ្ឍពិធីសារស្តង់ដារដើម្បីសម្របសម្រួលសុខដុមនីយកម្មនៃការតាមដាន AMR និងការប្រើឱសថប្រឆាំងមេរោគនៅក្នុងមនុស្សនិងសត្វ។

*ការប្រើដោយប្រុងប្រយ័ត្ននៃឱសថប្រឆាំងមេរោគ*

1. រៀបចំបង្កើតនិងអនុវត្តមគ្គុទ្ទេសក៍ជាតិស្តីពីការប្រើឱសថប្រឆាំងមេរោគដោយប្រុងប្រយ័ត្ននៅក្នុងបសុសត្វដោយមានការចូលរួមពីផ្នែកពាក់ព័ន្ធផ្សេងៗ។
2. ធ្វើការផ្សព្វផ្សាយមគ្គុទ្ទេសក៍ទាំងនេះ និងផ្តល់ការបណ្តុះបណ្តាលដល់ពេទ្យសត្វនិងកសិករអំពីការប្រើប្រាស់មគ្គុទ្ទេសក៍នេះ។
3. រៀបចំបង្កើតយន្តការសវនកម្មនិងព័ត៌មានត្រឡប់ ដើម្បីបង្កើនការគោរពតាមមគ្គុទ្ទេសក៍ទាំងនេះ។
4. រៀបចំនិងអនុវត្តយុទ្ធសាស្ត្រអប់រំដែលសង្កត់ធ្ងន់លើសារៈសំខាន់និងអត្ថប្រយោជន៍នៃការប្រើឱសថដោយប្រុងប្រយ័ត្នប្រឆាំងមេរោគ។
5. លើកទឹកចិត្តដល់ការអនុវត្តមគ្គុទ្ទេសក៍ Codex Alimentarius និង OIE(អង្គការសុខភាពសត្វពិភពលោក) ដែលទាក់ទងនឹងAMR។

*សុខភាពសត្វកាន់តែប្រសើរ*

1. ដាក់ឲ្យអនុវត្តវិធានការនានាដើម្បីលើកកម្ពស់សុខភាពសត្វ និងកាត់បន្ថយតម្រូវការរកការព្យាបាលដោយប្រើឱសថប្រឆាំងមេរោគដែលរួមបញ្ចូលទាំងការប្រើថ្នាំបង្ការប្រកបដោយប្រសិទ្ធភាព។
2. រៀបចំបង្កើតនិងអនុវត្តមគ្គុទ្ទេសក៍សម្រាប់ការគ្រប់គ្រងសុខភាពរបស់បសុសត្វដោយធានាការគោរពតាមគោលការណ៍អនាម័យនិងការចិញ្ចឹមល្អ។

## 6. លើកកម្ពស់ការបង្ការនិងការត្រួតពិនិត្យការចម្លងរោគ

*ក. អនុវត្តកម្មវិធីបង្ការនិងត្រួតពិនិត្យការចម្លងរោគនៅគ្រប់មូលដ្ឋានសុខាភិបាល*

*យុទ្ធសាស្ត្របង្ការនិងត្រួតពិនិត្យការចម្លងរោគ*

1. មូលដ្ឋានសុខាភិបាលត្រូវអនុវត្តមគ្គុទ្ទេសក៍ស្តីពីការបង្ការនិងត្រួតពិនិត្យការចម្លងរោគដើម្បីកាត់បន្ថយការចម្លងរោគក្នុងមន្ទីរពេទ្យ។

2. ផ្សព្វផ្សាយមគ្គុទ្ទេសក៍ស្តីពីការបង្ការនិងត្រួតពិនិត្យការចម្លងដល់សហគមន៍និងមូលដ្ឋានសុខាភិបាលឯកជន។
3. ផ្សព្វផ្សាយព័ត៌មានអំពីការប្រតិបត្តិអនាម័យល្អដល់សាធារណជនទូទៅដោយសហការជាមួយបុគ្គលិកសុខភាពសាធារណៈសង្គមស៊ីវិលនិងអង្គការសហគមន៍។

*ខ. លើកកម្ពស់និងវាយតម្លៃការអនុវត្តស្តង់ដារបង្ការនិងត្រួតពិនិត្យការចម្លងរោគ*

## *អនុវត្តស្តង់ដារបង្ការនិងត្រួតពិនិត្យការចម្លងរោគ*

1. មន្ទីរពេទ្យទាំងអស់ត្រូវមានក្រុមការងារបង្ការនិងត្រួតពិនិត្យការចម្លងរោគ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយជាតិស្តីពីការបង្ការនិងត្រួតពិនិត្យការចម្លងរោគនិងមគ្គុទ្ទេសក៍ស្តីពីការបង្ការនិងត្រួតពិនិត្យការចម្លងរោគសម្រាប់មូលដ្ឋានសុខាភិបាល។
2. ក្រសួងសុខាភិបាលត្រូវលើកកម្ពស់គុណភាពនិងសុវត្ថិភាពនៅក្នុងការថែទាំសុខភាពដើម្បីធ្វើឲ្យប្រសើរឡើងនូវសុវត្ថិភាពរបស់អ្នកជំងឺ បុគ្គលិកសុខាភិបាលនិងបរិស្ថាន។
3. ក្រសួងសុខាភិបាលត្រូវពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បីជួយទប់ស្កាត់ការរីករាលដាលជំងឺឆ្លងនៅក្នុងមូលដ្ឋានសុខាភិបាលព្រមទាំងឆ្លើយតបនឹងការគំរាមកំហែងចំពោះសុខភាពសាធារណៈ។
4. ក្រសួងសុខាភិបាលត្រូវជួយមូលដ្ឋានសុខាភិបាល នៅក្នុងការធ្វើការប៉ាន់ប្រមាណហានិភ័យនិងអនុវត្តយុទ្ធសាស្រ្តបង្ការនិងត្រួតពិនិត្យការចម្លងរោគសមស្រប។
5. មូលដ្ឋានសុខាភិបាលត្រូវធានាឲ្យមានបរិយាកាសគ្រប់គ្រាន់មួយសម្រាប់អនុវត្តការប្រតិបត្តិអនាម័យល្អ ប្រព័ន្ធខ្យល់ចេញចូលសមស្របកន្លែងលាងដៃនិងការជៀសវាងមនុស្សច្រើនកកកុញនៅមួយកន្លែង។
6. ជានិច្ចជាកាលត្រូវធ្វើការកំណត់អត្តសញ្ញាណបុគ្គលដែលឆ្លងរោគឲ្យទាន់ពេលវេលានិងធ្វើការគ្រប់គ្រងករណីឲ្យបានត្រឹមត្រូវ។
7. ផ្តល់ការបណ្តុះបណ្តាលដល់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល អំពីការបង្ការនិងត្រួតពិនិត្យការចម្លងរោគ និងចាក់ថ្នាំបង្ការការពារជំងឺផ្សេងៗដែលកើតមាន។

7. ជំរុញនវានុវត្តន៍និងការស្រាវជ្រាវនិងអភិវឌ្ឍន៍សម្រាប់ឧបករណ៍ថ្មី

*ភាពជាដៃគូក្នុងការសិក្សាស្រាវជ្រាវ*

1. ត្រូវធ្វើការពិនិត្យឡើងវិញលើគោលការណ៍ណែនាំស្តីពីការស្រាវជ្រាវដែលមានស្រាប់ ដែលការពារសិទ្ធិរបស់អ្នកជំងឺនិងផលប្រយោជន៍ជាតិរបស់ប្រទេសដើម្បីកំណត់ថាតើចាំបាច់ត្រូវបង្កើតគោនយោបាយបន្ថែមទៀតឬទេ។
2. រៀបចំរៀបវារៈស្រាវជ្រាវដែលបញ្ជាក់ពីអាទិភាពអំពី AMR ។
3. ក្រសួងសុខាភិបាល ត្រូវលើកទឹកចិត្តឲ្យមានការសិក្សាស្រាវជ្រាវក្នុងស្រុកទាក់ទងនឹងAMR តាមរយៈភាពជាដៃគូជាមួយអង្គការអប់រំនិងស្រាវជ្រាវឧស្សាហកម្មវិស័យសត្វនិងភាគីពាក់ព័ន្ធ។
4. បង្កើតគ្រឿងលើកទឹកចិត្តដើម្បីលើកទឹកចិត្តដល់សកម្មភាពស្រាវជ្រាវក្នុងចំណោមភាគីពាក់ព័ន្ធនានា។

*ធាតុចេញនៃការស្រាវជ្រាវ*

1. សកម្មភាពស្រាវជ្រាវត្រូវតែប្រែក្លាយទៅជាព័ត៌មានដែលមានសារៈប្រយោជន៍ដើម្បីណែនាំដល់គំនិតផ្តួចផ្តើមនានាដែលមានគោលបំណងទប់ស្កាត់ AMR ។
2. សកម្មភាពស្រាវជ្រាវត្រូវសង្កត់ធ្ងន់លើការអភិវឌ្ឍ និង/ឬការវាយតម្លៃលើឱសថប្រឆាំងមេរោគថ្មី និងតេស្តធ្វើរោគវិនិច្ឆ័យរហ័សនៅកន្លែងថែទាំផ្ទាល់។
3. របកគំហើញនិងផលិតផលដែលបានមកពីការស្រាវជ្រាវនឹងត្រូវបានផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងប្រទេសកម្ពុជា។

# ក្របខ័ណ្ឌអនុវត្តន៍

## I. ការទទួលខុសត្រូវរួម

ក្រុមការងារAMR WGត្រូវទទួលខុសត្រូវលើការអនុវត្តគោលនយោបាយជាតិសម្រាប់ទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅក្នុងប្រទេសកម្ពុជា (NPCAR)។ក្រុមការងារAMR WGត្រូវដឹកនាំការតាក់តែងគោលការណ៍ណែនាំបច្ចេកទេសនិងគោលនយោបាយនានាដែលទាក់ទងនឹងAMR។ក្រុមការងារនេះត្រូវធានាផងដែរនូវការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធដទៃទៀតនៅក្នុងក្រសួងសុខាភិបាលនិងរវាងក្រសួងសុខាភិបាលនិងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទអង្គការក្រៅរដ្ឋាភិបាលសមាគមវិជ្ជាជីវៈមូលដ្ឋានសុខាភិបាលនៅក្នុងវិស័យសាធារណៈនិងឯកជនភ្នាក់ងារផ្តល់ជំនួយអ្នកជំងឺអ្នកប្រើប្រាស់និងភាគីពាក់ព័ន្ធដទៃទៀត។

## II. តួនាទីនិងការទទួលខុសត្រូវរបស់ដៃគូដទៃទៀត

*អ្នកតាក់តែងគោលនយោបាយ និងអ្នករៀបចំផែនការនៅក្នុងរដ្ឋាភិបាល*

1. រៀបចំបង្កើតក្របខ័ណ្ឌច្បាប់មួយដើម្បីជំរុញការអនុវត្តវិធាននិងបទប្បញ្ញត្តិសំដៅទប់ស្កាត់ AMR ដោយប្រសិទ្ធភាពនិងដោះស្រាយផលវិបាកផ្នែកសុខភាពដែលពាក់ព័ន្ធ។

*គណៈវិជ្ជាជីវៈ*

1. ធានាការបដិបត្តិតាមច្បាប់និងប្រកបដោយក្រមសីលធម៌របស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដោយសហការជាមួយសមាគមវិជ្ជាជីវៈ។
2. អភិវឌ្ឍនិងអនុវត្តស្តង់ដារសម្រាប់ការចេញអាជ្ញាប័ណ្ណការចុះបញ្ជីនិងការអប់រំបន្តរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល។

*អ្នកប្រកបវិជ្ជាជីវៈសុខភាព*

1. ផ្តល់ការថែទាំប្រកបដោយគុណភាពដល់អ្នកជំងឺសំដៅបង្កើនលទ្ធផលសុខភាពជាអតិបរមា និងកាត់បន្ថយការចំណាយឲ្យនៅកម្រិតទាបបំផុត។
2. ផ្សព្វផ្សាយព័ត៌មាន និងផ្តល់ប្រឹក្សាដល់អ្នកជំងឺអំពីការប្រើប្រាស់ឱសថដោយសមស្របនិងប្រកបដោយការទទួលខុសត្រូវ ជាពិសេស ឱសថប្រឆាំងមេរោគ។
3. ធានាថាបុគ្គលិកសុខាភិបាលទាំងអស់គោរពតាមគោលការណ៍ណែនាំក្រមសីលធម៌នៃការប្រព្រឹត្តិវិជ្ជាជីវៈ។
4. គ្រូពេទ្យត្រូវចេញវេជ្ជបញ្ជាឱសថប្រឆាំងមេរោគសមស្របដោយមានការណែនាំច្បាស់លាស់ត្រឹមត្រូវនិងអាចយល់បាន ដល់អ្នកជំងឺ។
5. ពេទ្យសត្វត្រូវបញ្ឈប់ការប្រើឱសថសម្លាប់មេរោគ (អង់ទីប៊ីយ៉ូទិក) ជាសារធាតុជំរុញការលូតលាស់និងសម្រាប់បង្ការជំងឺនៅក្នុងបសុសត្វ។
6. ឱសថការីនិងអ្នកចែកថ្នាំត្រូវធានាថាឱសថប្រឆាំងមេរោគត្រូវបានទទួលពីប្រភពដែលមានការអនុញ្ញាតត្រឹមត្រូវរក្សាទុកដោយត្រឹមត្រូវនិងផ្គត់ផ្គង់ដោយមានវេជ្ជបញ្ជាតែប៉ុណ្ណោះ។
7. បុគ្គលិកមន្ទីរពិសោធន៍ត្រូវធានាភាពត្រឹមត្រូវភាពអាចជឿទុកចិត្តបាននិងភាពទាន់ពេលវេលានៃលទ្ធផល ព្រមទាំងប្រាស្រ័យទាក់ដោយប្រសិទ្ធភាពជាមួយគ្រូពេទ្យអំពីការជ្រើសរើសឱសថប្រឆាំងមេរោគសម្រាប់ការព្យាបាលអ្នកជំងឺ។មន្ទីរពិសោធន៍ត្រូវដាក់បញ្ចូលគ្នានូវទិន្នន័យ AMR ជាប្រចាំដើម្បីគាំទ្រដល់ការគ្រប់គ្រងផ្នែកគ្លីនិក។

*គ្រឹះស្ថានអប់រំនិងស្រាវជ្រាវ*

1. លើកកម្ពស់ការអប់រំនិងបណ្តុះបណ្តាលអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល។
2. អនុវត្តគំនិតផ្តួចផ្តើមនានាដើម្បីទប់ស្កាត់AMR តាមរយៈសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍។

*អ្នកផ្តល់សេវាអ្នកគ្រប់គ្រងស្ថាប័ននិងសហគមន៍*

1. អនុវត្តវិធានការត្រួតពិនិត្យការចម្លងរោគ ដើម្បីទប់ស្កាត់ការកើតឡើងនិងការរីករាលដាលនៃ AMR។

*សង្គមស៊ីវិលអ្នកប្រើប្រាស់សេវានិងអ្នកជំងឺ*

1. ផ្សព្វផ្សាយអំពីបញ្ហាAMR និងស្នើសុំចំណាត់ការពីអ្នកតាក់តែងគោលនយោបាយ និងភាគីពាក់ព័ន្ធដទៃទៀត។
2. ប្រើឱសថដោយសមស្របនិងប្រកបដោយការទទួលខុសត្រូវព្រមទាំងស្វែងព័ត៌មានឱសថដោយសកម្ម។
3. ចូលរួមនៅក្នុងការទទួលខុសត្រូវក្នុងការរាយការណ៍អំពីបញ្ហានានាដែលពាក់ព័ន្ធនឹងឱសថប្រឆាំងមេរោគ ( ឧទា. ហេតុការណ៍ប្រតិកម្មថ្នាំតម្លៃថ្លៃហួសហេតុឱសថក្លែងក្លាយ)។

*ការធ្វើរោគវិនិច្ឆ័យនិងឧស្សាហកម្មឱសថ*

1. ធ្វើការស្រាវជ្រាវនិងអភិវឌ្ឍឧបករណ៍សម្រាប់បង្ការនិងធ្វើរោគវិនិច្ឆ័យជំងឺឲ្យបានកាន់តែប្រសើរនិង ការរកឲ្យឃើញ AMR ទាន់ពេលវេលា។

## III. ក្របខ័ណ្ឌប្រតិបត្តិ

បន្ទាប់ពីគោលនយោបាយនេះត្រូវបានអនុម័តជាផ្លូវការក្រុមការងារAMR WG នឹងបង្កើតផែនការយុទ្ធសាស្ត្រមួយដែលរួមបញ្ចូលចំណុចដៅការត្រួតពិនិត្យតាមដានការវាយតម្លៃនិងដំណើរការពិនិត្យឡើងវិញលើ NPCAR ។គោលការណ៍ណែនាំជាក់លាក់នឹងបានបង្កើតឡើងដើម្បីគាំទ្រដល់ការអនុវត្តNPCAR ។

## IV. ការពិនិត្យឡើងវិញនិងការវាយតម្លៃ

គោលនយោបាយជាតិដើម្បីទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (NPCAR) នឹងត្រូវបានពិនិត្យឡើងវិញរៀងរាល់៥ឆ្នាំម្តងឬញឹកញាប់ជាងនេះទៅតាមការចាំបាច់។ក្រសួងសុខាភិបាលអាចសម្រេចចិត្តបង្កើតគណៈកម្មាធិការជាតិមួយដើម្បីពិនិត្យឡើងវិញនិងវាយតម្លៃគោលនយោបាយនេះ។